


# កុមាររងគ្រោះ ១២០ នាក់ នៅ PSE ទទួលបានអាហារូបត្ថម្ភ ពីមូលនិធិគ្រួសារ Herbalife

(ថ្ងៃទី 11 តុលា 2014, ម៉ោង 11:59:AM) | ដោយ: គូឡាប | ក- ក ក+ | Print

ភ្នំពេញ: មូលនិធិគ្រួសារ Herbalife (HFF) នឹងជួយដល់គម្រោងកម្មវិធីគាំទ្រ អាហារូបត្ថម្ភរបស់អង្គការ PSE នូវទឹកប្រាក់ចំនួន ១ ម៉ឺនដុល្លារ ក្នុងរយៈពេល១ឆ្នាំ ដើម្បីបង្កើនអាហារូបត្ថម្ភ ដល់កុមារចំនួន ១២០ នាក់ នៅក្នុងមណ្ឌលសេវាកម្ម សហគមន៍កុមារព្រែកទាល់ របស់អង្គការ PSE។

ឯកសារដែលទាក់ទងនឹង ការផ្តល់ជំនួយគាំទ្រ ចំពោះគម្រោងកម្មវិធីគាំទ្រ អាហារូបត្ថម្ភ របស់អង្គការ PSE នេះ បានត្រូវចុះហត្ថលេខា កាលពីព្រឹកថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៤ នៅទីស្នាក់ការ PES ស្ទឹងមានជ័យ ដោយលោក អ៊ុក សុវណ្ណ នាយករងកម្មវិធី នៃអង្គការដើម្បីភាពញញឹមនៃកុមារ PSE និងលោក ថាំង ឃៀន នាយកគ្រប់គ្រងជាន់ខ្ពស់ / អគ្គនាយកក្រុមហ៊ុន Herbalife កម្ពុជា-វៀតណាម និងថៃ ។

លោក អ៊ុក សុវណ្ណ បានមានប្រសាសន៍ថា អង្គការដើម្បីភាពញញឹមនៃកុមារ PSE គឺជាអង្គការមិនស្វែងរកប្រាក់ចំណេញ ដែលផ្តល់ដល់កុមារខ្វះខាត នូវអាហារ ការអប់រំ ទីជំរក និងការថែទាំជាដើម។ ថ្ងៃនេះ យើងបានទទួលនូវការឧបត្ថម្ភជាអាហារ ចំពោះកុមារ ១២០ នាក់ នៃអង្គការដើម្បីភាពញញឹមនៃកុមារ។ យើងមិនចង់ឃើញកុមារទាំងឡាយណា មានការស្រេកឃ្លាន ខ្វះអាហារ ដែលយើងមិនអាចបន្តការងារ ដោយជោគជ័យបាននោះទេ។ នេះជាគោលបំណងនៃ អង្គការដើម្បីភាពញញឹមនៃកុមារ ដើម្បីឲ្យកុមារមករៀន មានភាពសប្បាយ ដោយមិនមានការភ័យខ្លាច ក្នុងការអត់អាហារ។

លោក ថាំង ឃៀន បានមានប្រសាសន៍ថា យើងពិតជារីករាយណាស់ ក្នុងការបើក សម្ពោធ កម្មវិធី Casa Herbalife របស់យើងទី១ នៅប្រទេសកម្ពុជា ជាមួយនឹងអង្គការ PSE ដើម្បីជួយបង្កើនអាហារូបត្ថម្ភ និងការរស់នៅ របស់កុមារក្រីក្រ។ យើងជឿជាក់ថា ការទទួលបានអាហារូបត្ថម្ភត្រឹមត្រូវ គឺជាសមាសភាគមួយដ៏សំខាន់ សំរាប់ការ អភិវឌ្ឍន៍រាងកាយ និងសុខភាពកុមារ។ ការសម្ពោធកម្មវិធី Casa Herbalife នៅកម្ពុជានេះ កំពុងសបញ្ជាក់ អំពីការតាំងចិត្តរបស់យើង ក្នុងការចែករំលែក ជាមួយនឹងសហគមន៍ផងដែរ។ Herbalife គឺជាដៃគូដ៏ល្អឥតខ្ចោះជាមួយនឹង PSE។

លោកបានបន្តថា HFF គាំទ្រកម្មវិធី Casa Herbalife ជាង ១០០ កម្មវិធី នៅទូទាំងពិភពលោក និងផ្តល់នូវអាហារូបត្ថម្ភចាំបាច់ សំរាប់កុមារជាង ១២០,០០០ នាក់ នៅទូទាំងពិភពលោក តាមរយៈជំនួយប្រចាំឆ្នាំ ទៅឲ្យអង្គការក្រៅរដ្ឋាភិបាល និងអង្គការសប្បុរសធម៌ ៤ ដែលជួយគាំទ្រ ដល់កុមារដែលងាយរងគ្រោះ។

សូមបញ្ជាក់ថា បច្ចុប្បន្ន PSE កំពុងផ្តល់ជំនួយដល់ កុមារជាង ៧,០០០ នាក់ ក្នុងនោះមានកុមារប្រមាណ ៣,៣០០ នាក់ សិក្សានៅតាមសាលារដ្ឋ កុមារ ១,៥០០ នាក់ សិក្សានៅក្នុងកម្មវិធីអប់រំពន្លឿនសិក្សា កុមារ ១,៨០០ នាក់ សិក្សានៅក្នុងកម្មវិធី បណ្តុះ បណ្តាលវិជ្ជាជីវៈ និងកុមារប្រហែល ៥០០ នាក់ ទៀត កំពុងស្ថិតនៅក្នុងកម្មវិធីអប់រំ ជាក់លាក់ ដែលមានដូចជា ថ្នាក់សម្រាប់កុមារ ដែលមានពិការភាព មណ្ឌលថែទាំកុមារ សុខុមាលភាពទារក។ល។

ចំណែកក្រុមហ៊ុន Herbalife ជាក្រុមហ៊ុនអាហារបំប៉នអន្តរជាតិមួយ ដែលលក់ផលិតផលគ្រប់គ្រងទំងន់ អាហារបំប៉ន និងផលិតផលថែទាំ សុខភាពផ្ទាល់ខ្លួន ក្នុងបំណងគាំទ្រ ដល់ការរស់នៅ ប្រកបដោយសុខុមាលភាព។ ផលិតផលរបស់ក្រុមហ៊ុន ត្រូវបានលក់តាមបណ្តាញ សមាជិកឯករាជ្យ នៅក្នុងជាង ៩០ប្រទេស។V/S







CASA Herbalife


NUTRITION
PSE
POUR UN
SOURIRE







កុមាររងគ្រោះ ១២០ នាក់ នៅ PSE ទទួលបានអាហារូបត្ថម្ភ ពីមូលនិធិគ្រួសារ Herbalife

សម្រាប់ពត៌មានបន្ថែម សូមចុចលីងខាងក្រោមៈ

CEN News:
[http://www.cen.com.kh/local/%E2%80%8B%E1%9E%80%E1%9E%BB%E1%9E%98%E1%9E%B6%E1%9E%9A%E2%80%8B%E1%9E%9A%E1%9E%84%E1%9E%82%E1%9F%92%E1%9E%9A%E1%9F%84%E1%9F%87-%E1%9F%A1%E1%9F%A2%E1%9F%A0-%E1%9E%93%E1%9E%B6%E1%9E%80%E1%9F%8B-%E1%9E%93%E1%9F%85-PSE-%E1%9E%91%E1%9E%91%E1%9E%BD%E1%9E%9B%E1%9E%94%E1%9E%B6%E1%9E%93%E2%80%8B%E1%9E%A2%E1%9E%B6%E1%9E%A0%E1%9E%B6%E1%9E%9A%E1%9E%BC%E1%9E%94%E1%9E%8F%E1%9F%92%E1%9E%90%E1%9E%98%E1%9F%92%E1%9E%97-%E1%9E%96%E1%9E%B8%E2%80%8B%E1%9E%98%E1%9E%BC%E1%9E%9B%E1%9E%93%E1%9E%B7%E1%9E%92%E1%9E%B7%E2%80%8B%E1%9E%82%E1%9F%92%E1%9E%9A%E1%9E%BD%E1%9E%9F%E1%9E%B6%E1%9E%9A-Herbalife-13566514](http://www.cen.com.kh/local/%E2%80%8B%E1%9E%80%E1%9E%BB%E1%9E%98%E1%9E%B6%E1%9E%9A%E2%80%8B%E1%9E%9A%E1%9E%84%E1%9E%82%E1%9F%92%E1%9E%9A%E1%9F%84%E1%9F%87-%E1%9F%A1%E1%9F%A2%E1%9F%A0-%E1%9E%93%E1%9E%B6%E1%9E%80%E1%9F%8B-%E1%9E%93%E1%9F%85-PSE-%E1%9E%91%E1%9E%91%E1%9E%BD%E1%9E%9B%E1%9E%94%E1%9E%B6%E1%9E%93%E2%80%8B%E1%9E%A2%E1%9E%B6%E1%9E%A0%E1%9E%B6%E1%9E%9A%E1%9E%BC%E1%9E%94%E1%9E%8F%E1%9F%92%E1%9E%90%E1%9E%98%E1%9F%92%E1%9E%97-%E1%9E%96%E1%9E%B8%E2%80%8B%E1%9E%98%E1%9E%BC%E1%9E%9B%E1%9E%93%E1%9E%B7%E1%9E%92%E1%9E%B7%E2%80%8B%E1%9E%82%E1%9F%92%E1%9E%9A%E1%9E%BD%E1%9E%9F%E1%9E%B6%E1%9E%9A-Herbalife-13566514)